# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ：១៤៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការបែងចែកចំណាយថវិកាឆ្នោតរបស់រដ្ឋ តាមជំពូកនៃច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ . ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ . ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៨/០២០ . ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ឆ្នាំ ២០០៩

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៩ . ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ឆ្នាំ ២០០៩

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក.ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក. ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៨ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក . ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក. ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និង កែសំរួល នាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក . ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតំឡើងមីចាត់ការគយ និង រដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អោយទៅជាអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-តាមការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**មាត្រា១**:ឥណទានចំណាយនៃថវិកាទូទៅរបស់រដ្ឋដែលមានចែងនៅក្នុងច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ត្រូវបានបែងចែកតាមក្រសួង-ស្ថាប័ន និង តាមជំពូកនៃចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកា។

**មាត្រា២**:ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះតាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា៣**:រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលជាប្រធានក្រសួង-ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០២ . ខែ កញ្ញា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ ✓

**បានយកសេចក្តីជំរាបជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**